**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*** ***** ***

# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ម៉ូណូតា (ខេមបូឌា) ខូ អិលធីឌី
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១៥នាទី នៅក្នុងរោងចក្រ **ម៉ូណូតា (ខេមបូឌា) ខូ អិលធីឌី** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន នឹងតំណាងកម្មករ និយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៤២៧នាក់ រយៈពេល ២០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ ។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករ និយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ ឈ្នួល ៣០ដុល្លាសហរដ្ឋអាមេរិច ក្នុង១ខែ តាមសេចក្តីណែនាំលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ។

អង្គប្រជុំបានចប់នៅវេលាម៉ោង១៣ និង ៤៥នាទី នាថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤
កំពង់ស្ពឺ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០
**តំណាងក្រុមហ៊ុន**

**ស្នាមមេដៃតំណាងកម្មករ និយោជិត**